ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង ៖ ៣៧/១២-មេនហាតធេន
កាលបរិច្ឆេទនៃសេចក្តីបង្គាប់ ៖ ថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១២

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

**សមាសភាពក្រុមអាជ្ញាកណ្តាល**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក ៖ អ៊ឹង សុទ្ធី
អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត ៖ ស៊ីន គីមស៊ាន
ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ ៖ ប៉ែន ប៊ុនឈា

**ភាគីនៃវិវាទ**

**១- ភាគីនិយោជក**

ឈ្មោះ ៖ **សួនឧស្សាហកម្ម មេនហាតធេន**
អាសយដ្ឋាន ៖ ភូមិអំពិលលើ ឃុំអំពិល ស្រុកកំពង់សៀម ខេត្តកំពង់ចាម
ទូរស័ព្ទ ៖ ០១២ ៨៧១ ២២២ ទូរសារ ៖ គ្មាន
តំណាងភាគីនិយោជក ៖ អវត្តមាន

**២- ភាគីកម្មករនិយោជិត**

ឈ្មោះ ៖- **សហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា**
- **សហជីពសេរីកម្មករ នៃសួនឧស្សាហកម្ម មេនហាតធេន**

អាសយដ្ឋាន ៖ ភូមិអំពិលលើ ឃុំអំពិល ស្រុកកំពង់សៀម ខេត្តកំពង់ចាម
ទូរស័ព្ទ ៖ ០១២ ៩៣៥ ៤៥៦ ទូរសារ ៖ គ្មាន
តំណាងកម្មករនិយោជិត ៖ អវត្តមាន

## បញ្ហាវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

ក-ការសម្របសម្រួល ៖

ព្រមព្រៀង

- ចំណុចទី៦ ៖ ក្រុមហ៊ុនអនុញ្ញាតឱ្យកម្មករពាក់ស្បែកជើងរបស់ខ្លួនពេលកំពុងធ្វើការដើម្បីការពារសុវត្ថិភាព ប៉ុន្តែត្រូវពាក់ស្រោមជើងក្រណាត់បន្ថែមពីក្រៅដែលក្រុមហ៊ុនផ្តល់ជូន ។

- ចំណុចទី៨ ៖ ក្រុមហ៊ុនយល់ព្រមបើកប្រាក់ឈ្នួល និងប្រាក់បំណាច់ផ្សេងៗឱ្យកម្មករឈ្មោះ ជា ផល្លា ដែលក្រុមហ៊ុនបានបញ្ឈប់ពីការងារ ។

មិនព្រមព្រៀង

- ចំណុចទី១ ៖ សុំឱ្យក្រុមហ៊ុនបញ្ចូលកិច្ចសន្យាការងារដែលមានថិរវេលាកំណត់របស់កម្មករនិយោជិត ហើយធ្វើការហួសពីពីរឆ្នាំទៅជាកិច្ចសន្យាការងារមានថិរវេលាមិនកំណត់ (លិខិតបង្គាប់របស់អាជ្ញាកណ្តាលលេខ៧០/១០-មេនហាតធេន ចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១០) ។

- ចំណុចទី២ ៖ សុំឱ្យក្រុមហ៊ុនផ្តល់ប្រាក់ឧបត្ថមចំនួន ០២ ខែ ដល់កម្មករនិយោជិតដែលមានកិច្ចសន្យាការងារមានថិរវេលាមិនកំណត់ ហើយសុំលាឈប់ពីការងារ (លិខិតបង្គាប់របស់អាជ្ញាកណ្តាលលេខ ១៣២/១០-មេនហាតធេន ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១០) ។

- ចំណុចទី៣ ៖ សុំឱ្យក្រុមហ៊ុនរៀបចំកន្លែងដាក់យានជំនិះរបស់កម្មករនិយោជិតឱ្យបានគ្រប់គ្រាន់ និងមានវិធានការការពារឱ្យបានតឹងរឹង ហើយពេលមានការបាត់បង់សុំឱ្យក្រុមហ៊ុនទទួលខុសត្រូវ ។ លិខិតបង្គាប់របស់អាជ្ញាកណ្តាលលេខ ១២៨/១១-មេនហាតធេន ចុះថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១១) ។

- ចំណុចទី៤ ៖ សុំឱ្យក្រុមហ៊ុនអនុវត្តតាមបទបញ្ជាផ្ទៃក្នុងប្រការ ៥ ត្រង់ចំណុចទី១ ដែលចែងថា រង្វាន់ពលកម្មពេញម៉ោងក្នុងរយៈពេលពេញមួយឆ្នាំ និយោជិតកម្មករដែលមកធ្វើការមិនដែលមានការយឺតយ៉ាវ មិនដែលចេញមុនម៉ោង ហើយមានវត្តមានពេញម៉ោង (បូករួមទាំងការធ្វើការបន្ថែមម៉ោង) នោះនឹងត្រូវជូនរង្វាន់ជាទឹកប្រាក់ស្មើនឹងប្រាក់បៀវត្សចំនួន ០១ ខែ ឬលើសពី១ខែ ។ (លិខិតបង្គាប់របស់អាជ្ញាកណ្តាលលេខ ១៤៤/១១-មេនហាតធេន ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១១) ។

- ចំណុចទី៥ ៖ សុំឱ្យក្រុមហ៊ុនផ្តល់ប្រាក់បំណាច់បញ្ចប់កិច្ចសន្យាដែលមានថិរវេលាកំណត់ចំនួន ១៥ % នៃប្រាក់ឈ្នួលដែលកម្មករនិយោជិតបានបើក្នុងរយៈពេលនៃកិច្ចសន្យា ។ (លិខិតបង្គាប់របស់អាជ្ញាកណ្តាលលេខ ១៤៤/១១-មេនហាតធេន ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១១) ។

- ចំណុចទី៧ ៖ សុំឱ្យក្រុមហ៊ុនផ្តល់ប្រាក់អតីតភាពការងារដល់កម្មករនិយោជិតដែលមានកិច្ចសន្យាការងារមានថិរវេលាកំណត់ពេលបញ្ចប់ហើយបន្តឡើងវិញដោយមិនមានចន្លោះពេល (លិខិតបង្គាប់របស់អាជ្ញាកណ្តាលលេខ ១៤៤/១១-មេនហាតធេន ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១១) ។

THE ARBITRATION COUNCIL

ខ-ការផ្សះផ្សារ

ព្រមសះជា

- ចំណុចទី៣ ៖ ក្រុមហ៊ុនបើកប្រាក់ឈ្នួល និងប្រាក់បំណាច់ផ្សេងៗតាមច្បាប់ស្តីពីការក្នុងរយៈពេល ៤៨ ម៉ោងដល់កម្មករនិយោជិតបន្ទាប់ពីថ្ងៃបញ្ចប់កិច្ចសន្យាការងារ ។

មិនព្រមសះជា

- ចំណុចទី១ ៖ សុំឱ្យក្រុមហ៊ុនបន្តកិច្ចសន្យាការងារមានថិរវេលាកំណត់រយៈពេល ២ ឆ្នាំ ដល់តំណាងកម្មករនិយោជិតបន្ទាប់ពីបានបញ្ចប់កិច្ចសន្យាការងារមានថិរវេលាកំណត់រយៈពេល ៦ ខែ ។

- ចំណុចទី២ ៖ សុំឱ្យក្រុមហ៊ុនទទួលយកតំណាងកម្មករ ប្រតិភូបុគ្គលិក ដែលក្រុមហ៊ុនបញ្ចប់កិច្ចសន្យាការងារនោះបានចូលធ្វើការវិញ និងបន្តកិច្ចសន្យាការងារដល់តំណាងកម្មករ ប្រតិភូបុគ្គលិក ដែលក្រុមហ៊ុនមានគំរោងបញ្ចប់កិច្ចសន្យាការងារ ។

- ចំណុចទី៤ ៖ សុំឱ្យក្រុមហ៊ុនអនុវត្តកិច្ចព្រមព្រៀងចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១០ រាល់ពេលបញ្ចប់កិច្ចសន្យាការងាររួចបន្តកិច្ចសន្យាការងារឡើងវិញនៅថ្ងៃទី១ និយោជកដោះស្រាយប្រាក់ឈ្នួលជូននៅថ្ងៃទី១០ ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ (ខ) (មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិក ក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១៣៦ កប/ប្រក ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១១ (អាណត្តិទី៩) ។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី២ (ក) នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការមិនសះជាលេខ ០៩/១២ កប.កច ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១២ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១២ ។

## សវនាការ និង សង្ខេបនីតិវិធី

ទីកន្លែងសវនាការ ៖ ក្រុមប្រឹក្សាអាជ្ញាកណ្តាល ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ ។

កាលបរិច្ឆេទសវនាការ ៖ ថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ២០១២ (វេលាម៉ោង ២ រសៀល ) ។

បញ្ហានៃនីតិវិធី ៖

នៅថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១២ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកំពង់ចាម បានទទួលលិខិតជូនដំណឹងសុំធ្វើកូដកម្មរបស់តំណាងកម្មករនៃសួន ឧស្សាហកម្ម មេនហាតធេន។ នៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១២ មន្ទីរ

ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកំពង់ចាមបានអញ្ជើញភាគីតំណាងកម្មករ និងតំណាងនិយោជកមកសាកសួរព័ត៌មានតាមនីតិវិធី។ នៅថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១២ មន្ត្រីផ្សះផ្សាវិវាទការងារបានអញ្ជើញភាគីទាំងពីរមកធ្វើការសម្របសម្រួល និងផ្សះផ្សានៅមន្ទីរការងារ ដោយទទួលបានលទ្ធផលដូចខាងក្រោម ៖

- ការសម្របសម្រួល ៖ សះជាចំនួន២ ចំណុច និងមិនសះជាចំនួន៦ចំណុច។
- ការផ្សះផ្សា ៖ សះជាចំនួន១ចំណុច និងមិនសះជាចំនួន៣ចំណុច។

ចំណុចមិនសះជាទាំងអស់ត្រូវបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១២ តាមរបាយការណ៍មិនសះជាលេខ ០៩/១២ កប.កច ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១២។

បន្ទាប់ពីបានទទួលសំណុំរឿងរួចមក លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលបានធ្វើការកោះអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិតមកសវនាការ និងធ្វើការផ្សះផ្សាលើករណីមិនសះជា នៅថ្ងៃទី០៥ ខែមីនា ឆ្នាំ២០១២ វេលាម៉ោង ១៤ និង ០០ នាទី រសៀល។ ប៉ុន្តែភាគីកម្មករនិយោជិត និងនិយោជកមិនបានចូលរួមសវនាការក្រុមប្រឹក្សាអាជ្ញាកណ្តាលទេ។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណាដូចខាងក្រោម ៖

**ភស្តុតាង**

សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖ គ្មាន

**ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន**

ក- ឯកសារបានទទួលពីភាគីនិយោជក ៖

- កិច្ចព្រមព្រៀងប្រជុំដោះស្រាយវិវាទការងារនៅការិយាល័យសមាគមន៍កាត់ដេររវាងសួនឧស្សាហកម្ម មេនហាតធេន និងសហជីពសេរីកម្មករ ចុះថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០១២ ។

ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖ គ្មាន

គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅសួនឧស្សាហកម្ម មេនហាតធេន លេខ ០៩/១២ កប.កច ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១២។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមរបស់សួនឧស្សាហកម្ម មេនហាតធេន ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១២។

ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមកិច្ចប្រជុំមុនសវនាការលេខ ២០៣ កប/អក/វក/លកអ. ចុះថ្ងៃទី ២៣ ខែកុម្ភៈ ឆ្នាំ២០១២ ។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមកិច្ចប្រជុំមុនសវនាការលេខ ២០៤ កប/អក/វក/លកអ. ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១២ ។

THE ARBITRATION COUNCIL

៣- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការលេខ ២២១ កប/អក/វក/លកអ. ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១២ ។

៤- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការលេខ ២២២ កប/អក/វក/លកអ. ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១២ ។

៥- កំណត់ហេតុស្តីពីការចាប់ឆ្នោតជ្រើសរើសអាជ្ញាកណ្តាលពីបញ្ជីឈ្មោះអាជ្ញាកណ្តាលស្មើដោយសហជីពកម្មករនិយោជិត ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១២ ។

**អង្គហេតុ**

ក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនអាចរកឃើញអង្គហេតុ ទាក់ទងនឹងការទាមទារនៅក្នុងសំណុំរឿងនេះទេ ដោយហេតុថា ភាគីកម្មករនិយោជិតគ្រាន់តែផ្តល់កិច្ចព្រមព្រៀង ចុះថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០១២ ជូនក្រុមប្រឹក្សាអាជ្ញាកណ្តាលមុនពេលសវនាការ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានពិនិត្យឃើញថា កិច្ចព្រមព្រៀងនេះមានចំណុចវិវាទមួយចំនួនសះជានឹងគ្នា និងចំណុចវិវាទមួយចំនួនទៀតនៅមិនទាន់សះជានឹងគ្នានៅឡើយទេ ដូចជាចំណុចវិវាទទី១ជាដើម។ ប៉ុន្តែ នៅថ្ងៃសវនាការ ភាគីកម្មករនិយោជិត និងភាគីក្រុមហ៊ុន មិនបានអញ្ជើញមកចូលរួមសវនាការទេ ហើយក៏មិនបានផ្តល់នូវមូលហេតុណាមួយឡើយ ពោលគឺអវត្តមានដោយគ្មានមូលហេតុ។

**ហេតុផលនៃសេចក្តីសម្រេច**

តាមប្រការ ២១ នៃប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ " *ក្នុងករណីភាគីណាមួយបានទទួលការអញ្ជើញត្រឹមត្រូវហើយ តែបែរជាខកខានមិនបានមកបង្ហាញខ្លួន នៅចំពោះមុខក្រុមអាជ្ញាកណ្តាលដោយគ្មានបង្ហាញមូលហេតុត្រឹមត្រូវ ក្រុមអាជ្ញាកណ្តាលអាចបន្តដំណើរការរបស់ខ្លួន ក្នុងពេលដែលភាគីនោះអវត្តមាន ឬអាចបញ្ចប់ដំណើរការអាជ្ញាកណ្តាលដោយចេញជាសេចក្តីបង្គាប់* " ។

បន្ថែមពីនេះទៀត វិធាន ៤.៧ នៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅក្នុងឧបសម្ព័ន្ធនៃប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ចែងថា "*ប្រសិនបើភាគីណាមួយមិនបានបង្ហាញខ្លួន ឬមិនមានអ្នកតំណាងក្នុងដំណើរការអាជ្ញាកណ្តាល ក្រុមអាជ្ញាកណ្តាលអាចបន្តដំណើរការរបស់ខ្លួនក្នុងអវត្តមានរបស់ភាគីនោះ ឬអាចបញ្ចប់ដំណើរការអាជ្ញាកណ្តាល ដោយចេញជាសេចក្តីបង្គាប់។ ក្នុងករណីណាមួយ ក្រុមអាជ្ញាកណ្តាលត្រូវតែបំពេញតាមលក្ខខណ្ឌថា ភាគីវិវាទបានទទួលការជូនដំណឹងយ៉ាងត្រឹមត្រូវអំពីកាលបរិច្ឆេទ ពេលវេលា និងទីកន្លែងនៃដំណើរការអាជ្ញាកណ្តាល មុនពេលធ្វើសេចក្តីសម្រេចរបស់ខ្លួន* " ។

ផ្អែកលើប្រការ ២១ និងវិធាន ៤.៧ ខាងលើនេះ នៅក្នុងសេចក្តីបង្គាប់លេខ ៣០/០៥-មួរៀ, លេខ ១៦/០៧- ឡូទូសតី, លេខ ២៧/០៧-អ៊ីម និង វ៉េ ៣, លេខ ៩៥/០៨-យ៉ុង វ៉ា ទី១, លេខ ១៣២/០៨-ជី អែច ជី, លេខ ១៣៨/០៨-ម៉ាលីន, លេខ ១៥១/០៨-វិល សិន, លេខ ០៩/០៩-នីមបឹស ថិចថាយ៍ លេខ ០១/១០-ឌិននីតិច, លេខ ៣០/១០-ក្លូប័ល អាប៉ារែល ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា មានលក្ខខណ្ឌបី ដែលត្រូវបំពេញ មុនពេល

THE ARBITRATION COUNCIL

ដែលក្រុមប្រឹក្សាអាជ្ញាកណ្តាលអាចបញ្ចប់ដំណើរការអាជ្ញាកណ្តាល ដោយចេញជាសេចក្តីបង្គាប់បាន។ លក្ខខណ្ឌទី១ គឺភាគីត្រូវបានជូនដំណឹងដោយត្រឹមត្រូវ។ លក្ខខណ្ឌទី២ គឺភាគីមិនបានបង្ហាញខ្លួននៅក្នុងសវនាការ និងលក្ខខណ្ឌទី៣ គឺភាគីមិនបានផ្តល់មូលហេតុសម្រាប់ការមិនបង្ហាញខ្លួន។

ដូច្នេះ នៅក្នុងសំណុំរឿងនេះក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាថា តើលក្ខខណ្ឌទាំងបីត្រូវបានបំពេញដែរឬទេ?

លក្ខខណ្ឌទី ១ ៖ ភាគីត្រូវបានជូនដំណឹងដោយត្រឹមត្រូវ

ដូចដែលបានបញ្ជាក់ក្នុងវិធាន ៤.៧ ខាងលើ ក្រុមអាជ្ញាកណ្តាលអាចបន្តដំណើរការរបស់ខ្លួនក្នុងករណីអវត្តមានរបស់ភាគីនោះ ឬអាចបញ្ចប់ដំណើរការអាជ្ញាកណ្តាល ដោយចេញជាសេចក្តីបង្គាប់ប្រសិនបើភាគីណាមួយមិនបានបង្ហាញខ្លួន ឬមិនមានអ្នកតំណាងក្នុងដំណើរការអាជ្ញាកណ្តាល ក្នុងករណីដែលភាគីវិវាទត្រូវបានជូនដំណឹងយ៉ាងត្រឹមត្រូវអំពីកាលបរិច្ឆេទ ពេលវេលា និងទីកន្លែងនៃដំណើរការអាជ្ញាកណ្តាល។ ក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានរកឃើញថា លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលបានធ្វើលិខិតអញ្ជើញជាផ្លូវការ (ជាលាយលក្ខណ៍អក្សរ) ទៅកាន់ភាគីនិយោជក លេខ ២២១ កប/អក/វក/លកអ ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១២ និង ទៅកាន់ភាគីកម្មករនិយោជិត លេខ ២២២ កប/អក/វក/លកអ ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១២។ លិខិតអញ្ជើញទាំងនេះ ត្រូវបានធ្វើឡើងតាមនីតិវិធីជាប្រចាំរបស់លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល។ លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលបានទំនាក់ទំនងទៅកាន់ភាគីទាំងពីរអំពីកាលបរិច្ឆេទ ពេលវេលា និងទីកន្លែងនៃថ្ងៃសវនាការ តាមរយៈលិខិតអញ្ជើញជាលាយលក្ខណ៍អក្សរ និងតាមទូរស័ព្ទ។

ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ភាគីទាំងពីរត្រូវបានជូនដំណឹងដោយត្រឹមត្រូវពីសវនាការក្រុមប្រឹក្សាអាជ្ញាកណ្តាល ដូចនេះ លក្ខខណ្ឌទី១ ត្រូវបានបំពេញ។

លក្ខខណ្ឌទី ២ ៖ ភាគីមិនបានបង្ហាញខ្លួននៅក្នុងសវនាការ

ប្រការ ១៩ នៃប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ចែង ថា *"ភាគីវិវាទអាចមកបង្ហាញខ្លួនទៅចំពោះមុខក្រុមអាជ្ញាកណ្តាលដោយផ្ទាល់ខ្លួន ឬដោយមានអ្នកអម ឬតំណាងដោយមេធាវី ដែលជាសមាជិកនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ឬដោយបុគ្គលផ្សេងទៀត ដែលបានទទួលការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីភាគីនោះ"* ។

បន្ថែមពីនេះទៀត ប្រការ ២០ នៃប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ក៏បានចែងថា *"ក្នុងអំឡុងពេលនៃដំណើរការរបស់ក្រុមអាជ្ញាកណ្តាល ..... ភាគីទាំងនេះ ត្រូវតែចូលរួមគ្រប់កិច្ចប្រជុំទាំងឡាយ ដែលក្រុមអាជ្ញាកណ្តាលបានអញ្ជើញឱ្យចូលរួម"* ។

នៅក្នុងករណីនេះ ភាគីកម្មករនិយោជិត និងភាគីនិយោជកមិនបានមកចូលរួមសវនាការ ហើយក៏មិនបានចាត់ឱ្យមានអ្នកតំណាង (ដូចជាខាងសហព័ន្ធសហជីព ឬមេធាវី) ដើម្បីតំណាងពួកគេនៅក្នុងសវនាការនោះទេ។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា លក្ខខណ្ឌទី២ ក៏ត្រូវបានបំពេញដែរ។

THE ARBITRATION COUNCIL

លក្ខខណ្ឌទី ៣ ៖ ភាគីមិនបានផ្តល់មូលហេតុត្រឹមត្រូវសម្រាប់ការមិនបង្ហាញខ្លួន

ដូចដែលបានបញ្ជាក់ក្នុងប្រការ ២១ នៃប្រកាសខាងលើ ក្រុមអាជ្ញាកណ្តាលអាចបន្តដំណើរការរបស់ខ្លួនក្នុងពេលដែលភាគីនោះអវត្តមាន ឬអាចបញ្ចប់ដំណើរការអាជ្ញាកណ្តាលដោយចេញជាសេចក្តីបង្គាប់ក្នុងករណីភាគីបានទទួលការអញ្ជើញត្រឹមត្រូវហើយ តែបែរជាខកខានមិនបានមកបង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្តាលដោយគ្មានបង្ហាញមូលហេតុត្រឹមត្រូវ។ ក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ភាគីកម្មករនិយោជិត និងភាគីនិយោជកអវត្តមាន និងមិនបានផ្តល់មូលហេតុត្រឹមត្រូវអ្វីទាំងអស់ដល់លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលអំពីការមិនចូលរួមសវនាការនោះទេ។ ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា លក្ខខណ្ឌទី៣ ក៏ត្រូវបានបំពេញដែរ។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចបិទសំណុំរឿងលេខ ៣៧/១២ - សួនឧស្សាហកម្ម មេនហាតធេន នេះ ដោយភាគីកម្មករនិយោជិត និងភាគីនិយោជកអវត្តមាននៅពេលសវនាការ។

យោងតាមការបង្ហាញភស្តុតាង អង្គហេតុ អង្គច្បាប់ និងហេតុផល ដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចចេញសេចក្តីបង្គាប់ដូចតទៅ ៖

## សម្រេច និង បង្គាប់

បិទសំណុំរឿងលេខ ៣៧/១២ - សួនឧស្សាហកម្ម មេនហាតធេន។

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក ៖

ឈ្មោះ ៖ **អ៊ុំ សុទ្ធី**

ហត្ថលេខា: ----------------------------------------

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត ៖

ឈ្មោះ ៖ **ស៊ីន គឹមស៊ាន**

ហត្ថលេខា: ----------------------------------------

ប្រធានក្រុមអាជ្ញាកណ្តាល ៖

ឈ្មោះ ៖ **ម៉េន ម៉ុនឈា**

ហត្ថលេខា: ----------------------------------------